**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧៤ **អយក.ហ**

**សូមគោរពជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេចផ្តល់ទិដ្ឋាការលើមុខសញ្ញាចំណាយមួយចំនួនដែលពាក់ព័ន្ធនឹងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឥសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ ចាប់ពីឆ្នាំ២០២១ តទៅ។

**យោង ៖** -លិខិតលេខ២៧៤ សហវ.ហក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-លិខិតលេខ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-លិខិតលេខ៧០៦ សជណ.អវ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ កន្លងមក ការគ្រប់គ្រងហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឥសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងសាលាអនុវត្តន៍ ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ ដោយឡែក ចំពោះរំហូរនៃការឆ្លងឯកសារផ្សេងៗនៅតាមមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ដោយប្រើប្រាស់ក្របខណ្ឌពេលវេលាខ្លី ព្រមទាំងបានបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តថវិកា ជាពិសេសពេលទម្លាក់ថវិកាគឺទាន់ពេលវេលា ដែលជាហេតុធ្វើឱ្យការអនុវត្តសកម្មភាពការងារស្របជាមួយផែនការអភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងសាលាអនុវត្តន៍បានល្អប្រសើរ។

រាជរដ្ឋាភិបាល បានឯកភាពជាគោលការណ៍ផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤ (ខេត្តកណ្តាល ព្រៃវែង តាកែវ និងកំពង់ចាម) មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឥសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការខេត្តចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពនៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡាវិញ តាមស្មារតីនៃលិខិតលេខ៧០៦ សជណ.អវ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ទន្ទឹមនឹងនេះ ដើម្បីបន្តនិរន្តរភាពនៃការអនុវត្តថវិកាឱ្យ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

មានសង្គតិភាពទៅនឹងការអនុវត្តកន្លងមក  ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យនិងសម្រេចផ្តល់ទិដ្ឋាការលើមុខសញ្ញាចំណាយដែលអាទិភាពនិងចាំបាច់បំផុត ព្រមទាំងមានគោលបេបច្បាស់លាស់មួយចំនួន ដូចខាងក្រោម៖

-ថវិកាដំណើរការរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងសាលាអនុវត្តន៍

-ថវិកាប្រជុំប្រចាំសប្តាហ៍របស់សាលាមត្តេយ្យសិក្សាអនុវត្តន៍

-ថវិកាប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍របស់សាលាបឋមសិក្សាអនុវត្តន៍

-ថវិកាប្រជុំតាមកម្រងសាលារៀនរបស់សាលាបឋមអនុវត្តន៍

-ថវិកាប្រជុំប្រចាំខែរបស់សាលាមធ្យមសិក្សាចំណេះទូទៅអនុវត្តន៍

-ថវិកាអាហារូបករណ៍សិស្សក្រីក្រជួបការលំបាករបស់សាលាអនុវត្តន៍

-ថវិកាអាហារូបករណ៍គរុសិស្សដែលកំពុងសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

-រង្វាន់សិស្សពូកែរបស់សាលាអនុវត្តន៍

-ថវិកាសម្រាប់សាងសង់បង្គន់អនាម័យនិងប្រព័ន្ធទឹកស្អាតរបស់សាលាអនុវត្តន៍

-ថវិកាបំប៉នគ្រូបង្រៀនកម្រិតបឋមដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ  សូម **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពនិងអនុញ្ញាតជាគោលការណ៍ បានប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា  ដើម្បីពិនិត្យនិងសម្រេចផ្តល់ទិដ្ឋាការលើមុខសញ្ញាចំណាយខាងលើ ចាប់ពីឆ្នាំ២០២១ តទៅដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន "

-កាលប្បវត្តិ

-ឯកសារ.នាយកដ្ឋានហិរញ្ញវត្ថុ